# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០១ បប**

## បទបញ្ជារបស់រាជរដ្ឋាភិបាល

## ស្តីពីការចាត់វិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាប

នៅក្នុងពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលសង្កេតឃើញថា នៅក្នុងភូមិសាស្ត្រនៃខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប រួមមានខេត្ត : កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ និងខេត្តកំពង់ឆ្នាំង នៅមានការមើលស្រាល និងឈានទៅដល់មានការឃុបឃិត ឬអនុញ្ញាតឱ្យមានការសាងសង់ជាអាងទឹក ជារមណីយដ្ឋាន ជាតំបន់ទេសចរណ៍ ។ល។ ដែលជាហេតុធ្វើឱ្យមានការរំលោភយ៉ាងធន់ធ្ងរដល់ព្រៃលិចទឹក និងប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងដល់លំនឹងធម្មជាតិ ជម្រកមច្ឆជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងប្រព័ន្ធជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

ដើម្បីធានាបាននូវនិរន្តរភាពបរិស្ថានធម្មជាតិ និងប្រព័ន្ធជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ រាជរដ្ឋាភិបាល សូមដាក់បទបញ្ជាដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដូចខាងក្រោម :

១- អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំងត្រូវដឹកនាំគណៈកម្មការចម្រុះថ្នាក់ខេត្ត ចុះរំលាយចោលទាំងស្រុង ឬកែសម្រួលបច្ចេកទេសលើបណ្តាអាងទឹកដែលបានសាងសង់ឡើងនៅក្នុងតំបន់ ២ និងតំបន់ ៣ ជុំវិញបឹងទន្លេសាប ។

២- រាល់គម្រោងអភិវឌ្ឍន៍ ឬការសាងសង់សំណង់នានាដែលត្រូវអនុវត្តក្នុងតំបន់បឹងទន្លេសាប ដាច់ខាតត្រូវមានគម្រោងប្លង់មេដែលបានធ្វើការសិក្សាត្រឹមត្រូវ ច្បាស់លាស់ និងទទួលបាននូវការយល់ព្រមជាមុនពីក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៣- អភិបាល នៃគណៈអភិបាលខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ត្រូវមានវិធានការទប់ស្កាត់ឱ្យខាងតែបាននូវការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត នៅក្នុងតំបន់ ២ និងតំបន់ ៣ ជុំវិញបឹងទន្លេសាប ។

៤- អភិបាល នៃគណៈអភិបាលខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខរាជរដ្ឋាភិបាលចំពោះការអនុវត្តន៍មិនបានសម្រេចនូវបទបញ្ជារបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងចំណុច ១ ចំណុច ២ និងចំណុច ៣ នៃបទបញ្ជានេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**